ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៦០ សរ

# សារាចរ

## ស្តីពី

## ការគ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារធាតុគីមី

កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចេញនូវអនុក្រឹត្យ និងលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា ជាពិសេសផលិតផលចំណីអាហារដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកមួយចំនួន ដែលមានប្រើសារធាតុគីមី ដើម្បីក្លែងបន្លំគុណភាព ។ រាជរដ្ឋាភិបាល បានធ្វើការផ្សព្វផ្សាយ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាប អំពីផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ព្រមទាំងបានដឹកនាំកំលាំងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យរកឃើញ និងបានធ្វើការកំទេចចោលនូវផលិតផលដែលខូចគុណភាព និងផលិតផលមួយចំនួនដែលមានប្រើសារធាតុគីមីហួសកំរិត ។

ប៉ុន្តែ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ ក៏នៅតែមានសកម្មភាពប្រើប្រាស់សារធាតុគីមី លើផលិតផលចំណីអាហារ និងទំនិញមួយចំនួនដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកកំពុងចរាចរ និងដាក់លក់នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។ អំពើទាំងនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋ បើសិនជាការគ្រប់គ្រង និងវិធានការត្រួតពិនិត្យ ពុំត្រូវបានអនុវត្តឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាពនោះទេ ។

ដើម្បីធ្វើការគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបការប្រើសារធាតុគីមីលើផលិតផលចំណីអាហារដែលកំពុងនាំចូល និងផលិតនៅតាមរោងចក្រ មូលដ្ឋានសិប្បកម្ម និងកំពុងចរាចរលើទីផ្សារ ក៏ដូចជាចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងតាមសាលារៀន ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាល ដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម :

១- គណៈកម្មាធិការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម ដែលដើរតួនាទីជាគណៈកម្មាធិការ Codex ជាតិផងនោះ ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ខិតខំពង្រឹងការអនុវត្តការងារតាមតួនាទី និងភារកិច្ចក្នុងការត្រួតពិនិត្យគុណភាពផលិតផលជាប្រចាំលើទំនិញនាំចូល និងផលិតផលក្នុងស្រុក ដែលកំពុងផលិត និងកំពុងចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរខេត្ត ក្រុង ដោយត្រូវពង្រឹងនាយកដ្ឋានកាំកុងត្រូល ទីចាត់ការគយ និងរដ្ឋាករ និងកងកំលាំងប្រដាប់អាវុធតាមព្រំដែន ដើម្បីទប់ស្កាត់ការនាំចូលទំនិញដែលមានសារជាតិគីមី ទំនិញគេចពន្ធនៅតាមច្រករបៀងតាមព្រំដែន ព្រោះទំនិញគេចពន្ធទាំងនោះភាគច្រើនជាទំនិញដែលមានប្រើសារជាតិគីមីពុល ឬជាទំនិញខូចគុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ។

៣- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យ និងចុះយកសំណាក ដើម្បីយកមកពិសោធរកគុណភាពនៃផលិតផលនៅតាមរោងចក្រ សហគ្រាស សិប្បកម្មតាមខេត្ត ក្រុង ទូទាំងប្រទេសឱ្យបានជាប់ជាប្រចាំ ។

៤- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងសុខាភិបាល ដោយចាត់តាំងមន្ត្រីមានសមត្ថកិច្ចចុះទៅពិនិត្យកន្លែងលក់ដូរចំណីអាហារនៅតាមសាលារៀនទូទាំងប្រទេស ជាពិសេសសាលាបឋមសិក្សា និងខិតខំអនុវត្តតាមសារាចរណែនាំ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាកន្លងមក ដោយត្រូវពង្រីកនូវកម្មវិធីអប់រំអនាម័យ និងសុវត្ថិភាព ចំណីអាហារដល់គ្រូបង្រៀន សិស្ស និស្សិត ឱ្យបានគ្រប់ខេត្ត ក្រុង និងគួរបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅគ្រប់កំរិតសិក្សា ។

៥- ក្រសួងសុខាភិបាល ត្រូវត្រួតពិនិត្យជាប្រចាំនៅតាមរោងចក្រ សហគ្រាសផលិតឱសថក្នុងប្រទេស គ្រប់គ្រងឱសថស្ថាន និងឱសថស្ថានរងទាំងអស់ ដើម្បីរកឱ្យឃើញនូវឱសថដែលក្លែងក្លាយ និងឱសថដែលហួសរយៈពេលប្រើប្រាស់ ។ ទន្ទឹមនេះ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់បញ្ជីអនុញ្ញាតឱ្យនាំចូលឱសថដល់សមត្ថកិច្ច ដែលត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែន ដើម្បីជួយទប់ស្កាត់ការនាំចូលឱសថខុសច្បាប់ ។

៦- ក្រសួងទេសចរណ៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល និងសមត្ថកិច្ចនៃក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធក្នុងការចុះត្រួតពិនិត្យម្ហូបអាហារនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន និងអាហារដ្ឋាននៅទូទាំងប្រទេស ដើម្បីធានាសុវត្ថិភាពចំណីអាហារជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ។

៧- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវខិតខំណែនាំផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងច្បាស់លាស់ដល់ប្រជាកសិករ អំពីរបៀបប្រើប្រាស់សារជាតិគីមី និងថ្នាំសំលាប់សត្វល្អិតទៅលើផលិតផលកសិកម្ម ដំណាំស្រូវ កសិដ្ឋានកន្លែងចិញ្ចឹមសត្វគ្រប់ប្រភេទ និងអនាម័យសត្តឃាតដ្ឋាន ។

៨- រាជបណ្ឌិតសភាកម្ពុជា ត្រូវសហការជាមួយក្រសួងព័ត៌មាន ក្នុងការដឹកនាំរៀបចំខ្លឹមសារ ដើម្បីធ្វើការផ្សព្វផ្សាយ អប់រំដល់សាធារណជន ស្តីពីសុវត្ថិភាពចំណីអាហារ តាមវិទ្យុ ទូរទស្សន៍ និងបណ្តាញព័ត៌មានឱ្យបានទូលំទូលាយ ដោយសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។

៩- ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវធ្វើបញ្ជីកំណត់អំពីសារធាតុគីមីណាដែលហាមឃាត់មិនឱ្យនាំចូល មិនឱ្យប្រើប្រាស់ ឬអនុញ្ញាតឱ្យនាំចូលតែមានកំរិត និងកំណត់អំពីសមត្ថកិច្ចដែលជាអ្នកអនុញ្ញាត ហើយត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល)

រងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ទីចាត់ការគយ និងរដ្ឋាករ) ដែលទទួលភារកិច្ចត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និងចម្លងមកទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ។

១០- ក្រសួង ស្ថាប័ន ត្រូវពង្រឹងការងារអភិបាលកិច្ចល្អដល់មន្ត្រីរាជការក្រោមឱវាទ ឱ្យខិតខំផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងផ្នែកឯកជនឱ្យកាន់តែប្រសើរឡើង ជាពិសេសមន្ត្រីភ្នាក់ងារត្រួតពិនិត្យគុណភាពផលិតផល ដែលផលិតក្នុងរោងចក្រ សិប្បកម្ម សហគ្រាស កសិដ្ឋាន និងទំនិញដែលកំពុងចរាចរលើទីផ្សារ ព្រមទាំងនៅច្រកទ្វារព្រំដែន ដោយបង្កើនការផ្សព្វផ្សាយអប់រំ ដើម្បីឱ្យអ្នកផលិត និងអ្នកប្រើប្រាស់កាន់តែមានការយល់ដឹងពីផលប៉ះពាល់ដល់សុខភាព ។

ទទួលបាននូវសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព ។ fu

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ